លេខ ១៧ ចេញផ្សាយថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២២

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចស្តីពីការចុះត្រួតពិនិត្យលើបុគ្គលរាយការណ៍ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ទំព័រទី១
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ទំព័រទី២
- ពិធីចុះ MOU រវាង **ន.ប.ធ.** និង IFA ទំព័រទី២
- កិច្ចប្រជុំអន្តរនិយ័តករនៃ **អ.ស.ហ.** ទំព័រទី៣
- កិច្ចប្រជុំការងាររវាង **ន.ប.ធ.** ជាមួយក្រុមការងារក្រុមហ៊ុន PwC ទំព័រទី៤
- កិច្ចប្រជុំស្តីពី ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្រុមគោលដៅទទួលផល និងការផ្សព្វផ្សាយអំពីទម្រង់ឯកសារ និងនីតិវិធីក្នុងការដកប្រាក់កម្ចីរបស់គម្រោង ACSEP សមាសភាគទី១ ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយថ្នាក់ដឹកនាំនៃក្រុមហ៊ុន ភីភី លីង ស៊ុយរីធី ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារនៃអគ្គនាយកដ្ឋានពន្ធដារ ទំព័រទី៦
- ប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២២ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣ ទំព័រទី៦
- ចូលរួមកម្មវិធីចុះ MOU រវាងន.ម.ក. ជាមួយ (CDI) និងក្រុមហ៊ុន MOONXBT GLOBAL LIMITED ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយទីប្រឹក្សារបស់ (ADB) ទំព័រទី៧
- កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១១ ទំព័រទី៧
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែតុលា និងប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ទំព័រទី៨
- កម្មវិធី "ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថានជាផ្លូវការ" ទំព័រទី៨
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំកម្រងបទប្បញ្ញត្តិគតិយុត្តជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ" ទំព័រទី៩
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុនហ្វីលីពត្រាស់ធី ឯ.ក ទំព័រទី៩
- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "គោលការណ៍ណែនាំ និងនិតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំ និងការអនុវត្តថវិកាកម្មវិធីរបស **ន.ប.ធ.**" ទំព័រទី១០
- ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា My First Stock" ទំព័រទី១០
- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ **ន.ប.ធ.**" ទំព័រទី១១
- កម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌល បុរីកុមារ ក្រុងព្រះសីហនុ ទំព័រទី១២
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុន កាណាត្រាស ឯ.ក និងក្រុមហ៊ុន Technology Solution Development TSD Co.,LTD (TSD) ទំព័រទី១៣
- កិច្ចប្រជុំអន្តរនិយ័តករនៃ **អ.ស.ហ.** ទំព័រទី១៣


## កិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចស្តីពីការចុះត្រួតពិនិត្យលើបុគ្គលរាយការណ៍ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT)

នារសៀលថ្ងៃចន្ទ ៨កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចស្តីពីការចុះត្រួតពិនិត្យលើបុគ្គលរាយការណ៍ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងមានការអញ្ជើញចូលរួមពីឯកឧត្តមប្រតិភូ ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករពាក់ព័ន្ធចំណុះឱ្យ **អ.ស.ហ.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖កិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចស្តីពីការចុះត្រួតពិនិត្យលើបុគ្គលរាយការណ៍ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT)។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ

នាព្រឹកថ្ងៃអង្គារ ៩កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋាន។

ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង និយ័តករបរធនបាលកិច្ច និង វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA)

នាព្រឹកថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងលោក **ម៉ុន សុន្ទរវឌ្ឍ** នាយករង នៃវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA) នៅទីស្តីការអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្នុងក្របខណ្ឌនៃការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ **ន.ប.ធ.** បានចាប់ដៃគូយុទ្ធសាស្ត្រជាមួយនឹង IFA ដែលជាគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ កិច្ចសហប្រតិបត្តិការនេះក៏នឹងផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹង និងដកស្រង់យកបទពិសោធន៍ការងារផ្ទាល់ជាមួយនិយ័តករបរធនបាលកិច្ច ក៏ដូចជានឹងផ្តល់ឱកាសអាទិភាពដល់មន្ត្រីនៃ **ន.ប.ធ.** ដែលមានបំណងបង្កើនសមត្ថភាព និងចំណេះដឹងបន្ថែម ជាពិសេសពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុផងដែរ។

កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពី តំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.**, ថ្នាក់ដឹកនាំជាន់ខ្ពស់ សាស្ត្រាចារ្យ និងនិស្សិត នៃ IFA។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

សូមបញ្ជាក់ថា បរធនបាលកិច្ច គឺជាចំណងគតិយុត្ត ដែលក្នុងនោះ បរធនបាលទាយក (ម្ចាស់ទ្រព្យ) ប្រគល់ទ្រព្យរបស់ខ្លួនឱ្យបរធនបាល (អ្នកជំនាញវិជ្ជាជីវៈ និងមានអាជ្ញាបណ្ណ) ឱ្យធ្វើការគ្រប់គ្រង ចាត់ចែង និងថែរក្សាសុវត្ថិភាព ឬថែរក្សាទុកជំនួសដើម្បីជាប្រយោជន៍ដល់បរធនបាលទាយកវិញ ឬដល់ភាគីផ្សេងទៀត។




រូបភាព៖ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង និយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA)។

## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃពុធ-ព្រហស្បតិ៍ ១០-១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៥-៦ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខាវី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យទៅលើរបៀបវារៈចំនួនបួនរួមមាន៖ សេចក្តីព្រាងអនុក្រឹត្យស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និង សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច" របស់ **ន.ប.ធ.**, សេចក្តីណែនាំស្តីពីយន្តការ និងនីតិវិធីតាមដានការអនុវត្តអនុសាសន៍សវនកម្មអនុលោមភាពរបស់អង្គភាពសវនកម្មផ្ទៃក្នុង, "គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម" និងសេចក្តីព្រាងប្រកាសស្តីពី "ការដោះស្រាយវិវាទក្នុងប្រព័ន្ធសន្តិសុខសង្គម" របស់និយ័តករសន្តិសុខសង្គម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** និងមានការចូលរួមពីឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888







រូបភាព៖ កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.**។

## កិច្ចប្រជុំការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមការងារក្រុមហ៊ុន PwC

នាព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញ បានទទួលជួបប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមការងារនៃក្រុមហ៊ុន PwC តំណាងដោយលោក **នៅ រ៉េមី**, Associate Partner, លោក **Vijay Bhaskar Aleti**, Associate Director, លោកស្រី **កែវ កល្យាណ**, Manager និងលោក **ឡាញ់ ពិទូរ្យ**, Senior Consultant ដែលទទួលបន្ទុកជាអ្នកពិគ្រោះយោបល់លើការរៀបចំសេចក្តីព្រាងបច្ចុប្បន្នភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០២១-២០៣០) ដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចសម្រាប់ផ្តល់ជាធាតុចូលទៅក្នុងសេចក្តីព្រាងបច្ចុប្បន្នភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០២១-២០៣០)។




រូបភាព៖កិច្ចប្រជុំការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមការងារក្រុមហ៊ុន PwC។

## កិច្ចប្រជុំស្តីពី ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្រុមគោលដៅទទួលផល និងការផ្សព្វផ្សាយអំពីទម្រង់ឯកសារ និងនីតិវិធីក្នុងការដកប្រាក់កម្ចីរបស់គម្រោង ACSEP សមាសភាគទី១

នាព្រឹកថ្ងៃសុក្រ ១២កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) បានរៀបចំកិច្ចប្រជុំស្តីពី ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្រុមគោលដៅទទួលផល និងការផ្សព្វផ្សាយអំពីទម្រង់ឯកសារ និងនីតិវិធីក្នុងការដកប្រាក់កម្ចីរបស់គម្រោង ACSEP សមាសភាគទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជានាយកគម្រោង និង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ដោយផ្ទាល់នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងតាមប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះ បានរៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជាក់ឱ្យច្បាស់អំពីក្រុមគោលដៅទទួលផល និងផលិតផលដែលមានសក្តានុពល ដល់ស្ថាប័នហិរញ្ញវត្ថុ ដៃគូសហការក្រោមក្របខណ្ឌគម្រោង ACSEP, ផ្សព្វផ្សាយអំពីទម្រង់ឯកសារ និងនីតិវិធីក្នុងការដកប្រាក់កម្ចី (ESMS Template, Financial Request Template, Covenants and Risk Management Discussion) និងរៀបចំបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រី PIU និង PFI។

កិច្ចប្រជុំនេះ មានការចូលរួមពីសមាជិក និងទីប្រឹក្សាជាតិនិងអន្តរជាតិ របស់ PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ កសហវ, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូ។




រូបភាព៖ កិច្ចប្រជុំស្តីពី ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្រុមគោលដៅទទួលផល និងការផ្សព្វផ្សាយអំពីទម្រង់ឯកសារ និងនីតិវិធីក្នុងការដកប្រាក់កម្ចីរបស់គម្រោង ACSEP សមាសភាគទី១។

## កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយថ្នាក់ដឹកនាំនៃក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរីធី (PP Link Securities Co., Ltd.)

នារសៀលថ្ងៃសុក្រ ១២ កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញ បានទទួលជួបពិភាក្សាការងារតាមប្រព័ន្ធអនឡាញជាមួយថ្នាក់ដឹកនាំនៃក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរីធី (PP Link Securities Co., Ltd.) អំពីទិដ្ឋភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា បទដ្ឋានគតិយុត្តពាក់ព័ន្ធ ប្រតិបត្តិការនិងយន្តការបរធនបាលកិច្ច និងកាលានុវត្តភាពវិនិយោគ។




រូបភាព៖កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយថ្នាក់ដឹកនាំនៃក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរីធី (PP Link Securities Co., Ltd.) ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារនៃអគ្គនាយកដ្ឋានពន្ធដារ

នារសៀលថ្ងៃចន្ទ ១៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **ឯកឧត្តម នេខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងមន្ត្រីជំនាញ បានជួបប្រជុំពិភាក្សាជាមួយក្រុមការងារនៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយ **លោកជំទាវ ម៉ិន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យទៅលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នារវាងនិយ័តករបរធនបាលកិច្ច និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធតាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារនៃអគ្គនាយកដ្ឋានពន្ធដារ។

## ប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម ៩ខែដើមឆ្នាំ២០២២ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣

នាព្រឹកថ្ងៃអង្គារ ១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយលោក **យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញ បានចូលរួមប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២២ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣ ជូនក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកា" ដែលដឹកនាំដោយ **ឯកឧត្តម ឈឹម សារ៉េត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ ប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២២ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣។

## ចូលរួមកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ជាមួយវិទ្យាស្ថានអភិវឌ្ឍន៍ចិន (CDI) និងក្រុមហ៊ុន MOONXBT GLOBAL LIMITED

នាព្រឹកថ្ងៃអង្គារ ១ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម នេខ ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយលោក **រិន វឌ្ឍា** អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានចូលរួមកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "ការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា" រវាងនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងវិទ្យាស្ថានអភិវឌ្ឍន៍ចិន (CDI) និង "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យមូលបត្រនៅកម្ពុជា" **ន.ម.ក.** និងក្រុមហ៊ុន MOONXBT GLOBAL LIMITED ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា។




រូបភាព៖ កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) ជាមួយវិទ្យាស្ថានអភិវឌ្ឍន៍ចិន (CDI) និងក្រុមហ៊ុន MOONXBT GLOBAL LIMITED។

## កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយទីប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

នាព្រឹកថ្ងៃអង្គារ ១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក **យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ, លោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច និងមន្ត្រីជំនាញ បានទទួលជួបពិភាក្សាការងារជាមួយទីប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តំណាងដោយ Mr. John V Owens និងលោក **រស់ ខេមរា** ស្តីពី "ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា" ក្រោមការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។

កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចរបស់ប្រទេសកម្ពុជា ដើម្បីរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងពេញលេញ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយទីប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១១

នៅព្រឹកថ្ងៃពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) អមដោយ**ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.**, កញ្ញា**ឈាន សុខារី** ប្រធានយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច, លោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច ព្រមទាំងមន្ត្រីជំនាញរបស់ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការចូលរួមពី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ឯកឧត្តមអគ្គ-នាយកនិយ័តករក្រោមឱវាទនៃ **អ.ស.ហ.** និងសមាជិក-សមាជិកា **អ.ស.ហ.** តាមរយៈប្រព័ន្ធសន្និសីទវីឌីអូពីចំងាយ (Zoom)។

ជាលទ្ធផលនៃកិច្ចប្រជុំ របៀបវារៈចំនួនពីររបស់ **ន.ប.ធ.** បានទទួលការអនុម័តពីអង្គប្រជុំ ដែលក្នុងនោះមាន៖ (១). សេចក្តីព្រាងប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និង (២). សេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ច ដោយត្រូវធ្វើការកែសម្រួលលើទម្រង់ និងអក្ខរាវិរុទ្ធបន្ថែមមួយចំនួន មុនដាក់ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ចុះហត្ថលេខាដាក់ឱ្យអនុវត្តជាផ្លូវការ។




រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ. ។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែតុលា និងប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នារសៀលថ្ងៃព្រហស្បតិ៍ ៣ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែតុលា និងប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពី ប្រធានស្តីទីនាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ចទាំងអស់។ ជាមួយគ្នានេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ព្រមទាំងបានកោត-សរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។




រូបភាព៖កិច្ចប្រជុំបូកសរុបការងារប្រចាំខែកញ្ញា និងប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែតុលា និងប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។

## កម្មវិធី "ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ជាផ្លូវការ"

នៅព្រឹកថ្ងៃចន្ទ ៧រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)**, **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, លោក **ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញរបស់ **ន.ប.ធ.** បានចូលរួមកម្មវិធី "ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តតាមប្រព័ន្ធ

FMIS ទាំងស្រុងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន, និងដៃគូអភិវឌ្ឍន៍ តាមរយៈប្រព័ន្ធសន្និសីទវីឌីអូពីចំងាយ (Zoom)។






រូបភាព៖ កម្មវិធី "ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាពិគ្រោះយោបល់ស្ដីពី "ការរៀបចំកម្រងបទប្បញ្ញត្តិគតិយុត្តជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ"

នៅព្រឹកថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយលោក **ចេស ចាន់ដេត** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី "ការរៀបចំកម្រងបទប្បញ្ញត្តិគតិយុត្តជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងមានការចូលរួមពីឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** នៅសណ្ឋាគារ ភ្នំពេញ។

សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីរៀបចំកម្រងបទប្បញ្ញត្តិនេះឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងពេញលេញ ក៏ដូចជាសម្រាប់ជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់ស្ដីពី "ការរៀបចំកម្រងបទប្បញ្ញត្តិគតិយុត្តជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។

## កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុនហ្វីលីព ត្រាស់ធី ឯ.ក

នាព្រឹកថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ**ឯកឧត្តម ណើ សាគល** អគ្គនាយករង លោក **ហាយ សុវណ្ណា** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បាន

ទទួលជួបប្រជុំពិភាក្សាជាមួយក្រុមហ៊ុន ហ្វីលីព ត្រាស់ធី ឯ.ក ដែលដឹកនាំដោយលោក Ong Teong Hoon ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ហ្វីលីព ត្រាស់ធី អមដោយថ្នាក់ដឹកនាំនៃក្រុមហ៊ុន ហ្វីលីព ត្រាស់ធី នៅទីស្តីការនៃ **ន.ប.ធ.** ដើម្បីចូលជួបសម្តែងការគួរសម និងស្វែងយល់អំពីវឌ្ឍនភាពនៃវិស័យបរធនបាលកិច្ច ក៏ដូចជាកាលានុវត្តភាពនៅក្នុងវិស័យបរធនបាលកិច្ចផងដែរ។







រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុនហ្វីលីព ត្រាស់ធី ឯ.ក។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី "គោលការណ៍ណែនាំ និងនិតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីរបស ន.ប.ធ."

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "គោលការណ៍ណែនាំ និងនិតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីរបស **ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** នៅទីស្តីការ **អ.ស.ហ.**។




រូបភាព៖កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "គោលការណ៍ណែនាំ និងនិតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីរបស **ន.ប.ធ.**"។

## ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា My First Stock

នាព្រឹកថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធី ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា My First Stock ឆ្នាំ២០២២ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**"រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**) នៅផ្សារទំនើប អ៊ីអនភ្នំពេញ។

កម្មវិធីនេះនឹងប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ ២៣ ខែតុលា ឆ្នាំ២០២២ ព្រមទាំងទទួលបានលេខអត្តសញ្ញាណវិនិយោគិន និងគណនីជួញដូរមូលបត្រដោយឥតគិតថ្លៃ ជាដើម។




រូបភាព៖ កម្មវិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា My First Stock ដែលបានចូលរួមដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី "នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្រ្តីរបស់ ន.ប.ធ. និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ ន.ប.ធ."

នាព្រឹកថ្ងៃចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ **ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២២ នៅសណ្ឋាគារ ឆ្នេរសុខា (Sokha Beach) ខេត្តព្រះសីហនុ។ សិក្ខាសាលានេះ បានរៀបចំឡើងក្នុងគោលបំណង ដើម្បីជួយសម្រួលដល់មន្ត្រីរបស់ **ន.ប.ធ.** ក្នុងការរៀបចំលិខិតរដ្ឋបាលនានារបស់ **ន.ប.ធ.** ឱ្យមានភាពច្បាស់លាស់, ឆាប់រហ័ស និងមានស្តង់ដារួមគ្នាមួយ ព្រមទាំងបង្កើតឱ្យមាននូវសណ្តាប់ធ្នាប់ទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** តាមរយៈមុខងារដែលបានបង្កើតនៅក្នុងប្រព័ន្ធ ជាពិសេសជួយកាត់បន្ថយលើកិច្ចការគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** តាមបែបលើក្រដាស (Paper Base) ផងដែរ។







រូបភាព៖កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ញាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ **ន.ប.ធ.**" ដែលប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ។

## កម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌល បុរីកុមារ ក្រុងព្រះសីហនុ

នៅថ្ងៃអង្គារ ១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២, បន្ទាប់ពីបញ្ចប់កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ញាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) រួមដំណើរដោយ**ឯកឧត្តម នង ពិសិដ្ឋ**, **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** លោក **យុន វាសនា**, លោក **ប៉ូ សំអាង**, កញ្ញា **ឈាន សុខារី**, លោក **ហាយ សុវណ្ណា** ដែលជាថ្នាក់ដឹកនាំនាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** បានរៀបចំកម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌល បុរីកុមារ ក្រុងព្រះសីហនុ ដោយបានពាំនាំនូវអំណោយសប្បុរសធម៌ រួមមាន៖ អង្ករ, ប្រេងឆា, ទឹកស៊ីអ៊ីវ, ទឹកត្រី, ត្រីខ, ស្ករស, អំបិល, សម្ភារៈនិងថ្នាំពេទ្យ និងសម្ភារៈសិក្សាមួយចំនួនទៀត ព្រមទាំងបានផ្តល់សេចក្តីស្រលាញ់, សេចក្តីសង្ឃឹម, ការយកចិត្តទុកដាក់, ការចែករំលែកនូវបទពិសោធន៍ជីវិតនិងការងារ ក៏ដូចជាផ្តល់កម្លាំងចិត្តដល់កុមារនៅក្នុងមជ្ឈមណ្ឌល ដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំរបស់សង្គមនៅថ្ងៃអនាគត។



រូបភាព៖ ថ្នាក់ដឹកនាំ និងសហការីនៃ **ន.ប.ធ.** នៅក្នុងកម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌល បុរីកុមារ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

## កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុន កាណា ត្រាស ឯ.ក និងក្រុមហ៊ុន Technology Solution Development TSD Co.,LTD (TSD)

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងក្រុមការងារអភិវឌ្ឍប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន កាណា ត្រាស ឯ.ក និងក្រុមហ៊ុន Technology Solution Development TSD Co.,LTD (TSD) ដើម្បីធ្វើបទបង្ហាញអំពីប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធទ្រទ្រង់សម្រាប់ក្រុមហ៊ុនបរធនបាលលំហូរប្រតិបត្តិការ ទំហំការងារ ក៏ដូចជាកិច្ចដំណើរការបច្ចេកទេសឧត្តមានុវត្តន៍ និង ក្របខណ្ឌគតិយុត្តពាក់ព័ន្ធ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុន កាណា ត្រាស ឯ.ក និងក្រុមហ៊ុន Technology Solution Development TSD Co.,LTD (TSD)។

## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២, **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យទៅលើរបៀបវារៈចំនួនពីរ រួមមាន៖ ១).សេចក្តីព្រាងអនុក្រឹត្យស្តីពី "គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម" និង ២).សេចក្តីព្រាងប្រកាសស្តីពី "ការដោះស្រាយវិវាទក្នុងប្រព័ន្ធសន្តិសុខសង្គម" របស់និយ័តករសន្តិសុខសង្គម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ ក្នុងកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)